# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការចូលជាធរមាន និងប្រសិទ្ធភាពអនុវត្តកិច្ចព្រមព្រៀង ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរវាងកម្ពុជា-ឥណ្ឌូណេស៊ី



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ ជ្រាបថា កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (the Agreement between the Royal Government of Cambodia and the Government of the Republic of Indonesia for the Avoidance of Double Taxation and the Prevention of Fiscal Evasion with respect to Taxes on Income) ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៨/០១៩ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។ ថ្មីៗនេះរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី បានជូនដំណឹងជាផ្លូវការមករាជរដ្ឋាភិបាលកម្ពុជា អំពីការបញ្ចប់សព្វគ្រប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីដាក់កិច្ចព្រមព្រៀងនេះចូលជាធរមាន។ ដោយអនុលោមតាមមាត្រា២៩ ស្តីពីការចូលជាធរមាននៃកិច្ចព្រមព្រៀង ភាគីទាំងពីរបានធ្វើការជូនដំណឹងជាផ្លូវការទៅវិញទៅមកស្តីពីការបញ្ចប់សព្វគ្រប់ នូវនីតិវិធីផ្ទៃក្នុងរបស់ប្រទេសរៀងៗខ្លួន ដែលនាំឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន និងមាន

ប្រសិទ្ធភាពអនុវត្តចាប់ពី **ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិ ជ្រាប និងចូលរួមអនុវត្ត តាមសេចក្តីណែនាំ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល របស់អគ្គនាយកដ្ឋានពន្ធដារ និងបទដ្ឋានគតិយុត្តដទៃទៀតដែលមានជាធរមាន ឱ្យមានប្រសិទ្ធភាពខ្ពស់។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់នាយកដ្ឋាននីតិកម្មគោលនយោបាយសារពើពន្ធនិងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈទូរស័ព្ទលេខ ០១២ ៧៧៧ ៣៧៤, ០១៧ ២៦៦ ០៦៥, ០៩៩ ៦៦៧ ៤០៦ ឬចូលទៅកាន់គេហទំព័រ របស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ